**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាសម្ពោធព្រះវិហារកូរ៉េនៅភ្នំពេញថ្មី**
**ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៨**
***ប្រមូលមហាជនចម្រុះ ដើម្បីប្រកាសដំណឹងល្អ***

អត្ថបទទី១៖ ទក ១៨,១៥-២០
អត្ថបទទី២៖ ១ករ ៧,៣២-៣៥
ដំណឹងល្អ៖ មក ១,២១-២៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់សម្រាប់អាគារ និងព្រះវិហារថ្មីរបស់សហគមន៍ជនជាតិកូរ៉េ យើងមានអំណរសប្បាយរួមគ្នាថ្វាយអភិបូជាដើម្បីសម្ពោធសមិទ្ធផលថ្មីនេះ។ ប៉ុន្មានខែកន្លងមក សហគមន៍កូរ៉េបានសុំចេញពីផ្សារតូចមកថ្វាយអភិបូជានៅភ្នំពេញថ្មីនេះ ខ្ញុំសប្បាយចិត្តព្រោះថាដំបូងពេលខ្ញុំទិញដីនេះ ជាដីដាច់ស្រយាលគ្មានអ្នកមកទីនេះទេ។ នៅថ្ងៃអនាគតទីនេះ យើងនឹងសាងសង់វិសាលវិហារមួយដែលនឹងមានបន្ទប់អធិដ្ឋានសម្រាប់សហគមន៍អង់គ្លេស សហគមន៍បារាំង សហគមន៍កូរ៉េ ហេតុនេះហើយខ្ញុំថាធ្វើព្រះវិហារមិនបានទេ។ ក្រោយមកយើងបានឯកភាពគ្នា អាគារនេះជាមណ្ឌលអប់រំ ដែលជាន់ក្រោមសម្រាប់ព្រះសហគមន៍ភូមិភាគភ្នំពេញ មានការិយាល័យអប់រំ ការិយាល័យសុខភាព ការិយាល័យយុវជន និងមន្ទីរពេទ្យត្រចៀកតូចមួយ និងជាន់លើទុកសម្រាប់សហគមន៍កូរ៉េ។

ខ្ញុំសូមអរគុណលោកឪពុក អ៊ីនដុន ដែលបានសហការជាមួយខ្ញុំ ឥលូវនេះយើងមានអាគារមួយយ៉ាងស្អាត ដែលមានកន្លែងអប់រំជំនឿ កន្លែងអធិដ្ឋាន និងកន្លែងបម្រើសង្គមតាមរយៈព្រះសហគមន៍។ សូមអរគុណបងប្អូនទាំងអស់ ដែលបានជួយឧបត្ថម្ភទាំងលុយទាំងកម្លាំងកាយចិត្ត ដើម្បីឲ្យកន្លែងនេះទៅជាកន្លែងមួយយ៉ាងស្អាត ដើម្បីទទួលស្វាគមន៍គ្រីស្តបរិស័ទ និងជាពិសេសដើម្បីទទួលស្វាគមន៍វត្តមានរបស់ព្រះយេស៊ូ។ យើងសម្លឹងមើលព្រះយេស៊ូនៅក្នុងគម្ពីរដំណឹងល្អ របៀបព្រះយេស៊ូជារបៀបដើម្បីដឹកនាំជីវិតរបស់យើងជាគ្រីស្តបរិស័ទ៖

**ទីមួយ** ព្រះយេស៊ូបានប្រកាសដំណឹងល្អនៅធម្មសាលា ពីភូមិមួយទៅភូមិមួយ។

**ទីពីរ** ព្រះយេស៊ូបានប្រមូលមហាជនដែលស្តាប់ព្រះអង្គ ជាមួយក្រុមបូជាចារ្យ ជាមួយគណៈផារីស៊ី...

**ទីបី** សកម្មភាពរបស់ព្រះយេស៊ូ អប់រំ និងណែនាំឲ្យអ្នកជំងឺជាសាសៀយ។

ព្រះយេស៊ូដែលបានអប់រំ និងអធិដ្ឋាននៅក្នុងធម្មសាលា ដើម្បីណែនាំឲ្យបងប្អូនទទួលពន្លឺថ្មី។ យើងជួបជុំគ្នានៅក្នុងព្រះវិហារថ្មី ដើម្បីទទួលជីវិតតាមរយៈអធិដ្ឋាន តាមរយៈអគ្គសញ្ញានានា ដើម្បីទទួលការអប់រំ ជាពិសេសយុវជនទទួលការអប់រំជំនឿ។ ព្រះយេស៊ូមិននៅជាប់កន្លែងមួយ គឺព្រះអង្គបានចេញពីភូមិមួយទៅភូមិមួយ យើងមិនអាចសាងសង់ព្រះវិហារនៅគ្រប់ទីកន្លែង ប៉ុន្តែសំខាន់កុំឲ្យព្រះវិហារនេះទៅជាកន្លែងមួយចង្អៀតចង្អល់ដែលមានជនជាតិកូរ៉េ ធ្វើដូចម្តេចឲ្យកន្លែងនេះយើងអាចបើកទូលំទូលាយ ដើម្បីឲ្យបងប្អូនឯទៀតៗអាចចូលថែមទៀត និងដើម្បីឲ្យយើងប្រកាសដំណឹងល្អយ៉ាងពិត។ ព្រះវិហារនេះមិនមែនជាសាខាមួយរបស់ព្រះសហគមន៍នៅប្រទេសកូរ៉េ ប៉ុន្តែជាព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញបងប្អូនជាព្រះសហគមន៍តែមួយ ដែលកំពុងប្រកាសដំណឹងល្អអំពីព្រះយេស៊ូនៅប្រទេសកម្ពុជា។ ហេតុនេះហើយ ឲ្យយើងមានទំនាក់ទំនងដោយអញ្ជើញគ្នាទៅវិញទៅមកដើម្បីអធិដ្ឋាន ដើម្បីអប់រំជំនឿឲ្យគេស្គាល់អំពីប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍នៅប្រទេសកម្ពុជា ដោយអញ្ជើញបងប្អូនខ្មែរដើម្បីផ្តល់សក្ខីភាពអំពីព្រះសហគមន៍ខ្មែរដែលមានជីវិតថ្មីៗ។ ឲ្យយើងអញ្ជើញបងប្អូនកូរ៉េ ដើម្បីឲ្យគេផ្តល់សក្ខីភាពអំពីប្រវត្តិសាស្ត្រនៃព្រះសហគមន៍កូរ៉េដែរ ដើម្បីឲ្យព្រះសហគមន៍របស់យើងសហការគ្នានៅក្នុងជំនឿយ៉ាងពិតៗ។

ព្រះសហគមន៍កូរ៉េមានមោទនភាព ដោយសារជាគ្រីស្តបរិស័ទកូរ៉េទៅដល់ប្រទេសចិនដើម្បីទៅប្រកាសដំណឹងល្អមុនគេបង្អស់នៅទីនោះ។ ព្រះសហគមន៍កូរ៉េមានមោទនភាព ដោយសារមានមរណសាក្សីយ៉ាងច្រើន ដែលបានបូជាជីវិតដើម្បីឲ្យពេលនេះព្រះសហគមន៍មានជីវិតយ៉ាងបរិបូរណ៍។ ព្រះសហគមន៍កម្ពុជាមានមោទនភាព ដោយសារនៅសម័យប៉ុលពតយើងបាត់បង់អាគារ បាត់បង់អ្វីៗទាំងអស់ប៉ុន្តែជំនឿបានថែរក្សា។ ឈើឆ្កាងនេះ ជាសញ្ញាសម្គាល់នៃមរណសាក្សីនៃប្រទេសកម្ពុជា យើងនៅសល់តែឈើឆ្កាងនេះ

យើងបាត់បង់អ្វីៗទាំង ប៉ុន្តែជំនឿមិនបាត់បង់ទេ។ ហេតុនេះហើយ នៅពេលយើងចែករំលែកបទពិសោធនៃជំនឿរបស់យើង យើងអាចរឹងមាំនៅក្នុងជំនឿថែមទៀត។

ព្រះយេស៊ូបានប្រមូលមហាជន ក្រុមគណៈផារីស៊ី ណែនាំឲ្យគេឆ្ងល់ ណែនាំឲ្យគេអន់ចិត្ត ប៉ុន្តែពីពេលព្រះយេស៊ូប្រសូតហើយ នៅភូមិបេថ្លេហិមមានគ្រូគង្វាលផង មានហោរាចារ្យផង មានប្រជាជនផង រហូតដល់ព្រះយេស៊ូសោយទិវង្គតនៅសល់តែព្រះនាងម៉ារី លោកយ៉ូហាន ប្រជាជនមួយចំនួន និងទាហានដែរ។ តាមពិតព្រះយេស៊ូបានប្រមូលមហាជនចម្រុះ ដើម្បីប្រកាសដំណឹងល្អ។ ថ្ងៃនេះជាឱកាសមួយដើម្បីឲ្យយើងគិតដែរ សម្រាប់យើងដែលជាគ្រីស្តបរិស័ទកាតូលិក ដែលបានធ្វើការនៅក្នុងសង្គមកម្ពុជា យើងធ្វើយ៉ាងណាដើម្បីផ្តល់សក្ខីភាពអំពីជំនឿរបស់យើង។ យើងធ្វើយ៉ាងណា ដើម្បីបង្ហាញអំពីយុត្តិធម៌ សន្តិភាព ផលប្រយោជន៍រួមនៅក្នុងសង្គម វាជាតួនាទីរបស់យើងជាសាក្សីផ្ទាល់ ដើម្បីប្រមូលជាមនុស្សដែលយើងធ្វើការជាមួយសព្វថ្ងៃ ដែលមិនមែនជាគ្រីស្តបរិស័ទប៉ុន្តែឲ្យគេយល់អំពីតម្លៃ គុណធម៌នៃព្រះសហគមន៍របស់យើង។

រាជធានីភ្នំពេញ ជាកន្លែងមួយយ៉ាងស្អាតដែលមានកន្លែងរកស៊ីយ៉ាងច្រើន ប៉ុន្តែក៏នៅមានកូនក្មេងដែលគ្មានទីពឹង អ្នកក្រីក្រ ចាស់ជរាអនាថាមានច្រើនមែនទែន។ កុំឲ្យយើងភ្លេចបើកភ្នែកថែមទៀត យើងមានសមត្ថភាពដើម្បីធ្វើអាគារយ៉ាងស្អាត យើងមានសមត្ថភាពដើម្បីជួយគ្នាយ៉ាងច្រើន ប៉ុន្តែឲ្យយើងស្តាប់លឺសម្លេងរបស់បងប្អូនកំពុងយំ កំពុងមានទុក្ខលំបាកនិងអស់សង្ឃឹមនៅក្នុងជីវិតរបស់គេ។ ព្រះយេស៊ូបានជ្រើសរើសយើង ដើម្បីឲ្យយើងទៅជាសញ្ញាសម្គាល់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺប្រកាសដំណឹងល្អជូនដល់អ្នកក្រីក្រឲ្យគេរកឃើញសេចក្តីសង្ឃឹមនៅក្នុងជីវិតគេ។

ព្រះយេស៊ូអប់រំ ព្រះយេស៊ូបំភ្លឺ ព្រះយេស៊ូព្យាបាល សរុបមកព្រះយេស៊ូរំដោះមនុស្សឲ្យរកឃើញសេរីភាពយ៉ាងពិតប្រាកដ និងការសង្គ្រោះយ៉ាងពិត។ កន្លែងនេះយើងមានការិយាល័យសិក្សាដើម្បីអប់រំពីកុមាររហូតដល់សាកលវិទ្យាល័យ យើងមានការិយាល័យសុខភាពដើម្បីគិតអំពីមន្ទីរពេទ្យកាតូលិកភូមិភាគភ្នំពេញ យើងមានការិយាល័យយុវជនជំទង់ និងកុមារ ដើម្បីណែនាំឲ្យពួកគេទទួលការអប់រំនិងដឹងអំពីអត្ថន័យនៃតម្លៃជីវិតដ៏ថ្លៃថ្នូររបស់គេ។ កន្លែងនេះមានបងប្អូនដែលអធិដ្ឋានពីលើ នៅក្រោមយើងខិតខំអនុវត្តព្រះបន្ទូល

របស់ព្រះជាម្ចាស់យ៉ាងជាក់ស្តែង។ ថ្ងៃនេះ យើងបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បន្តិចទៀតយើងទទួលព្រះកាយព្រះគ្រីស្តនៅក្នុងព្រះវិហារដ៏ស្អាតនេះ ដូច្នេះខ្ញុំចង់ទុកសំណួរមួយសម្រាប់បងប្អូនថា **ខ្ញុំជាគ្រីស្តបរិស័ទ តើខ្ញុំធ្វើដូចម្តេចដើម្បីនិយាយដោយមានអំណាចដូចព្រះយេស៊ូ ដើម្បីណែនាំឲ្យបងប្អូនឯទៀតៗដែលគ្មានសេចក្តីសង្ឃឹមរកឃើញជីវិតថ្មី និងរកឃោះញអត្ថន័យនៃតម្លៃជីវិតរបស់គេ?** នៅក្នុងអត្ថបទទីមួយថា "**យើងនឹងធ្វើឲ្យមានព្យាការីម្នាក់យើងដាក់ព្រះបន្ទូលរបស់យើង នៅក្នុងមាត់របស់ព្យាការីនេះ លោកនឹងថ្លែងសេចក្តីទាំងប៉ុន្មានដែលយើងបង្គាប់**" ខ្ញុំជឿថាដូចព្រះនាងម៉ារីពីដើម នៅថ្ងៃនេះព្រះយេស៊ូបានជ្រើសរើសយើង ដើម្បីដាក់ព្រះបន្ទូលរបស់ព្រះអង្គនៅក្នុងមាត់យើងឲ្យយើងថ្លែងព្រះបន្ទូលដល់មនុស្សលោក។

ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់បងប្អូនទាំងអស់ដើម្បីឲ្យគ្រប់ពេលវេលាយើងភ្ញាក់ស្មារតី ដើម្បីថ្លែងដំណឹងល្អដល់អ្នកក្រីក្រ។អាម៉ែន៕